# ហត្ថលេខារបស់ខ្ញុំនៅលើកិច្ចព្រមព្រៀង MAINE SENIOR FARMSHARE ឆ្នាំ 2023 បង្ហាញថាខ្ញុំបានទទួលការណែនាំអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្ញុំ ក្រោមកម្មវិធីទីផ្សារអាហារូបត្ថម្ភកសិករសម្រាប់មនុស្សចាស់ (SFMNP) ដែលហៅ ថា MAINE SENIOR FARMSHARE PROGRAM (MSFP)ដែលបានពិពណ៌នានៅទីនេះ ។

## ភាពមានសិទ្ធិទទួលបានជំនួយរបស់អ្នកចូលរួម

- ខ្ញុំសូមបញ្ជាក់ថា ព័ត៌មានដែលខ្ញុំបានផ្តល់ជូនសម្រាប់ការកំណត់សិទ្ធិទទួលបានជំនួយ របស់ខ្ញុំគឺត្រឹមត្រូវ ។
- ខ្ញុំដឹងថា មន្ត្រីកម្មវិធី នឹងធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន នៅលើទម្រង់នេះ ព្រោះវាពាក់ព័ន្ធនឹងការទទួលជំនួយពីសហព័ន្ធ ។
- ខ្ញុំដឹងថា ចេតនាធ្វើសេចក្តីថ្លែងការណ៍មិនពិត ឬបំភាន់ ឬបំភាន់ដោយចេតនា លាក់បាំង ឬការរក្សាទុកអង្គហេតុ អាចនាំឱ្យខ្ញុំត្រូវបង់ប្រាក់សងដល់កម្មវិធី Maine Senior FarmShare ទៅតាម តម្លៃនៃអត្ថប្រយោជន៍អាហារដែលចេញឱ្យខ្ញុំមិនត្រឹមត្រូវ ហើយខ្ញុំអាចរងការកាត់ទោសរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ក្រោមច្បាប់រដ្ឋ និងសហព័ន្ធ ទៀតផង ។

## ព័ត៌មានលំអិតនៃកម្មវិធី FARMSHARE

- ខ្ញុំអាចចុះឈ្មោះជាមួយកសិករតែមួយនាក់ប៉ុណ្ណោះ ក្នុងមួយឆ្នាំ ។
- ខ្ញុំមិនបានរស់នៅក្នុងគ្រួសារតែមួយជាមួយកសិករនេះទេ ហើយខ្ញុំក៏មិនមែនជាសាច់ញាតិរបស់គ្រួសារនេះដែរ ។
- ខ្ញុំមានកាតព្វកិច្ចបំពេញចំណែករបស់ខ្ញុំនៅកសិដ្ឋាននេះ បើសិនជាមិនមានការបន្ធូរបន្ថយអ្វីមួយ អាចកើតឡើងទេនោះ ។
- ប្រសិនបើខ្ញុំបានមិនបំពេញចំណែករបស់ខ្ញុំ កសិករត្រូវប្រគល់ថវិកាដែលមិនបានចំណាយជូនរដ្ឋវិញ ។
- ប្រសិនបើកសិករ និងខ្ញុំ កំណត់បានថា ត្រឹមថ្ងៃទី 31 ខែសីហា ខ្ញុំនឹងមិនអាចប្រើជំនួយអស់ទេ នៅចុងបញ្ចប់នៃរដូវកាលនេះ នោះសមតុល្យដែលមិនបានប្រើរបស់ខ្ញុំ ត្រូវយកទៅចែកចាយដល់អ្នកដែលមានសិទ្ធិទទួលជំនួយផ្សេងទៀត ។
- ប្រសិនបើខ្ញុំមិនយកផលិតផលតម្លៃ 50 ដុល្លារទាំងអស់មកលោះ ទៅតាមកាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាទេ កសិករអាចប្រគល់ ឬមិនប្រគល់សមតុល្យ FarmShare ដែលនៅសេសសល់ដល់ខ្ញុំ ។
- ប្រសិនបើខ្ញុំ មិនអាចអនុវត្តសកម្មភាពទាំងនេះដោយខ្លួនឯងបានទេ ខ្ញុំអាចចាត់តាំងបុគ្គលម្នាក់ (កូនជឹង) ឱ្យធ្វើសកម្មភាពជំនួសខ្ញុំដោយបំពេញទម្រង់បែបបទកូនជឹង។ ទម្រង់នេះ មាននៅជាមួយកសិករ ហើយអាចបំពេញបានក្នុងអំឡុងពេលនៃផ្នែកណាមួយនៃរដូវកាល របស់កម្មវិធី ។

## ការមិនរើសអើង បណ្តឹង និងបណ្តឹងឧទ្ធរណ៍

- MSFP ត្រូវបានហាមឃាត់មិនឱ្យមានការរើសអើង ដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ភេទ (រួមទាំងអត្តសញ្ញាណយេនឌ័រ និងនិន្នាការផ្លូវភេទ) ពិការភាព អាយុ ឬការបន្ទោស ឬការសងសឹក ចំពោះសិទ្ធិពលរដ្ឋ ពីពេលមុន ។ ប្រសិនបើខ្ញុំមានអារម្មណ៍ថាសិទ្ធិរបស់ខ្ញុំត្រូវបានរំលោភ ខ្ញុំអាចដាក់ពាក្យបណ្តឹងអំពីការរើសអើង។
- ខ្ញុំដឹងថា ប្រសិនបើខ្ញុំ មានការតវ៉ាប្រឆាំងនឹងការអនុវត្តរបស់កសិករនោះ ខ្ញុំអាចដាក់ពាក្យបណ្តឹងតាមប្រៃសណីយ៍ទៅកាន់នាយកដ្ឋានកសិកម្ម អភិរក្ស និងព្រៃឈើ នៃរដ្ឋមេន (DACF), កម្មវិធី Maine Senior FarmShare, 28 State House Station, Augusta, ME 04333-0028, ឬតាមទូរស័ព្ទលេខ (207-446-5550) ឬទូរសារលេខ (207-287-7548) ។
- ខ្ញុំដឹងថា ខ្ញុំអាចប្តឹងឧទ្ធរណ៍ ចំពោះការសម្រេចចិត្តណាមួយដែលធ្វើឡើងដោយកម្មវិធី Maine Senior FarmShare ទាក់ទងនឹងសិទ្ធិទទួលបានជំនួយរបស់ខ្ញុំ ចំពោះកម្មវិធីទីផ្សារអាហារូបត្ថម្ភកសិករដែលជាមនុស្សចាស់ ។ បើមានសំណួរ សូមហៅទូរស័ព្ទទៅកាន់អ្នកគ្រប់គ្រងកម្មវិធី MSFP តាមលេខ (207-446-5550) ។

## ទិន្នន័យជាតិសាសន៍ និងពូជសាសន៍សម្រាប់កំណត់ត្រា USDA

ព័ត៌មានដែលបានស្នើសុំនៅលើទម្រង់កិច្ចព្រមព្រៀងសម្រាប់មនុស្សចាស់ កំពុងត្រូវបានចងក្រងដោយកម្មវិធី Maine Senior FarmShare ដើម្បីអនុលោមតាមបទប្បញ្ញត្តិនៃការរក្សាទុកកំណត់ត្រារបស់សហព័ន្ធ ។ អ្នកមិនចាំបាច់ផ្តល់ព័ត៌មាននេះទេ ប៉ុន្តែយើងខ្ញុំសូមលើកទឹកចិត្តឲ្យអ្នក ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយយើងខ្ញុំ ។

## ធនធាន និងឱកាសបន្ថែម

បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី Maine Senior FarmShare ក៏អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលជំនួយផ្សេងទៀតផងដែរ ។ សូមទាក់ទងទីភ្នាក់ងារកិច្ចការមនុស្សចាស់ ប្រចាំមូលដ្ឋានរបស់អ្នក ដោយហៅទូរស័ព្ទទៅលេខ **1-877-ELDERS-1** (1-877-353-3771) ស្ដីអំពីឱកាសទាំងអស់នេះ ឬធ្វើតេស្តដោយខ្លួនឯងតាមអនឡាញ នៅឯ ៖ [benefitscheckup.org](benefitscheckup.org) ។

កម្មវិធីទាំងនេះ អាចរួមបញ្ចូលនូវ ៖

ប្រាក់ចំណូលសន្តិសុខបង្គ្រប់ (SSI)
កម្មវិធីជំនួយអាហារូបត្ថម្ភបង្គ្រប់ (SNAP)
ជំនួយថវិកា និងបន្លែស្រស់ រដ្ឋមេន (Maine Harvest Bucks & Farm Fresh Rewards)
កម្មវិធីជំនួយថាមពលសម្រាប់ផ្ទះ (HEAP)
ការថែទាំសុខភាពរដ្ឋមេន (MaineCare)
ការធានារ៉ាប់រងសុខភាព $R_x$ ថ្មីស រដ្ឋមេន (Maine Rx Plus)
កម្មវិធីផ្តល់ថ្នាំក្នុងតម្លៃទាប
កម្មវិធីសន្សំ Medicare

## ធនធានផ្សេងៗទៀតរបស់រដ្ឋ

- ការិយាល័យសេវាមនុស្សចាស់ និងជនមានពិការភាព នៃនាយកដ្ឋានសេវាសុខភាព និងពលរដ្ឋ (OADS))
  - [maine.gov/dhhs/oads/](maine.gov/dhhs/oads/)
- កម្មវិធីជំនួយស្បៀងក្នុងគ្រាអាសន្ន (TEFAP)
  - [maine.gov/dacf/ard/tefap/index.shtml](maine.gov/dacf/ard/tefap/index.shtml)

## សេចក្តីថ្លែងការណ៍ អំពីការមិនរើសអើង របស់ USDA

អនុលោមតាមច្បាប់សិទ្ធិពលរដ្ឋ របស់សហព័ន្ធ និង  បទបញ្ញត្តិ និងគោលនយោបាយ នៃសិទ្ធិពលរដ្ឋ របស់ក្រសួងកសិកម្មសហរដ្ឋអាមេរិក (U.S. Department of Agriculture (USDA)), ស្ថាប័ននេះត្រូវបានហាមឃាត់មិនឱ្យមានការរើសអើង ដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ សញ្ជាតិកំណើត ភេទ (រួមទាំងអត្តសញ្ញាណយេនឌ័រ និងនិន្នាការផ្លូវភេទ) ពិការភាព អាយុ ឬការស្ដីបន្ទោស ឬការសងសឹកចំពោះសកម្មភាពសិទ្ធិពលរដ្ឋ ពីមុន ឡើយ ។

ព័ត៌មានអំពីកម្មវិធីនេះ អាចផ្តល់ជូនជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស ។ ជនមានពិការភាពជាប់ខ្លួន ដែលប្រើមធ្យោបាយទំនាក់ទំនងផ្សេងពីនេះ ដើម្បីទទួលបានព័ត៌មានរបស់កម្មវិធី (ដូចជា អក្សរស្ទាប ការបោះពុម្ពធំ ខ្សែអាត់សំឡេង ភាសាសញ្ញាអាមេរិក) សូមទាក់ទងរដ្ឋទទួលខុសត្រូវ ឬភ្នាក់ងារប្រចាំមូលដ្ឋានដែលគ្រប់គ្រងកម្មវិធី ឬមជ្ឈមណ្ឌល TARGET របស់ USDA តាមលេខ (202) 720-2600 (សំឡេង និង TTY) ឬទាក់ទង USDA តាមរយៈសេវាបញ្ជូនបន្តសហព័ន្ធ តាមលេខ (800) 877-8339

ដើម្បីដាក់ពាក្យបណ្តឹង អំពីការរើសអើងរបស់កម្មវិធី សូម បំពេញទម្រង់បែបបទ AD-3027, [បែបបទបណ្តឹងអំពីការរើសអើងរបស់កម្មវិធី USDA](https://www.usda.gov/sites/default/files/documents/USDA-OASCR%20P-Complaint-Form-0508-0002-508-11-28-17Fax2Mail.pdf) ដែលអាចរកបានតាមអនឡាញ នៅឯ ៖ [https://www.usda.gov/sites/default/files/documents/USDA-OASCR%20P-Complaint-Form-0508-0002-508-11-28-17Fax2Mail.pdf](https://www.usda.gov/sites/default/files/documents/USDA-OASCR%20P-Complaint-Form-0508-0002-508-11-28-17Fax2Mail.pdf), ពីការិយាល័យ USDA ណាមួយ ដោយហៅទៅលេខ (866) 632-9992 ឬដោយការសរសេរលិខិតទៅកាន់ USDA ។ សំបុត្រនេះ ត្រូវតែមានឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទរបស់អ្នកដើមបណ្តឹង និងការពណ៌នាជាលាយលក្ខណ៍អក្សរអំពីសកម្មភាពរើសអើង ដែលត្រូវបានចោទប្រកាន់យ៉ាងលម្អិតគ្រប់គ្រាន់ ដើម្បីជូនដំណឹងដល់ជំនួយការលេខាធិការទទួលបន្ទុកសិទ្ធិពលរដ្ឋ (ASCR) អំពីលក្ខណៈ និងកាលបរិច្ឆេទនៃការរំលោភសិទ្ធិពលរដ្ឋ ដែលត្រូវបានចោទប្រកាន់ ។ ទម្រង់ ឬលិខិត AD-3027 ដែលបានបំពេញរួចរាល់ ត្រូវតែដាក់ជូន USDA តាមរយៈ ៖

(1) **សំបុត្រ ៖**
U.S. Department of Agriculture
Office of the Assistant Secretary for Civil Rights
1400 Independence Avenue, SW
Washington, D.C. 20250-9410;

(2) **ទូរសារ ៖**
(833)256-1665 or (202) 690-7442; ឬ

(3) **អ៊ីម៉ែល ៖**
program.intake@usda.gov